«លោកគ្រូ! លោកគ្រូត្រូវតែចាប់ចងវាឲ្យជាប់ កុំមេត្តាវាថ្វី! វាលងបន្លាចមិនប្រណីរហូតដល់ខ្ញុំបម្រើបាវព្រាវរត់ចោលផ្ទះអស់ហើយ!»

ជំទាវអម្ពរនេះជាភរិយាអតីតលោកអភិបាលជុំខឿនដែលទើបនឹងចែកឋានទៅ។ ជំទាវពោលអង្វរអាចារ្យដួង ព្រោះក្នុងផ្ទះដ៏ធំស្កឹមស្កៃសល់ពីប្ដីមកមានវិញ្ញាណខ្មោចអុកឡុកមិនឈប់ឈរ។

លោកគ្រូដួងជាអាចារ្យចាប់ខ្មោចល្បីណាស់មកពីស្រុកលើ។ គាត់គ្រហឹមរង្គើកសម្លឹងមួយជុំ ទាំងទឹកមុខកាចខ្លាំងក្លា។

គាត់និយាយទៅកាន់ជំទាវស្រីថា៖

«ទុកចិត្តចុះ! ខ្ញុំមកដល់ហើយ! វាពូកែប៉ុណ្ណា ចាំមើលសាកជាមួយខ្ញុំម្ដង!»

សេដ្ឋីនីងក់ក្បាលយ៉ាងញាប់ទម្លាក់ចោលដោយអន្លើនូវភាពតក់ស្លុតទាំងប៉ុន្មាន ព្រោះមានទំនុកចិត្តខ្ពស់ជាងមុន។ គាត់នាំខ្ញុំកំដរស្នៀកក្បិនដើរត្រុកត្រុកតាមពីក្រោយអាចារ្យដួង។ លោកអាចារ្យចំណាស់ប្រមាណ៦០ឆ្នាំតែមានទឹកមុខមាំ។

ដៃគាត់កំពុងតែឱបបង្វេច និងដៃម្ខាងស្ទាបអង្កែលអង្កាជាខ្សែធំៗពាក់នៅលើកអាវ។

អង្គាំរបស់លោកអាចារ្យច្នៃពីថ្មកែវតែមានពណ៌ឈាមក្រហមជាំ។ វិមានឈើមួយនេះមានសរសេរហោចណាស់ក៏ពី១៥ទៅម្ភៃដែរ។

គាត់គ្រវីក្បាលព្រោះសសរត្រូវការបូជាត្រឹមត្រូវទើបនៅសុខសាន្ត ចុះបើមានសសរគគោកគដីបានអ្វីនឹងសែនព្រេនគ្រប់?

អាចារ្យរាប់សសរអស់ចិត្តអស់ចង់ ក៏ឱនមករាប់មេដៃកូនដៃខ្លួនវិញ។ គាត់ងើបមុខមកហើយសួរភ្លាម៖

«សេដ្ឋីទៅណាបានជាសេដ្ឋីនីនៅដោះស្រាយបញ្ហាព្រាយបិសាចតែម្នាក់ឯង?!»

«ប្ដីរបស់ខ្ញុំខូចកាលពីបីខែមុនហើយ!»

អាចារ្យថ្លោះមុខ។ ជំទាវបន្តឡើងទៀត៖

«ប៉ុន្តែគាត់ក៏បានដឹងរឿងនាងខ្មោចព្រៃដ៏សាហាវនេះដែរ! គ្រាន់តែគាត់មិនព្រមជឿសោះ ពីដំបូងៗ ព្រោះនាងនោះមិនលងមនុស្សប្រុសទេ! មានតែស្រីបម្រើរត់ប្រាសអាយ៉ូសអស់បានប្ដីខ្ញុំ

ព្រមជឿខ្លះ! ក្រោយមកគាត់ឈឺ ក៏មើលមិនទាន់! នាងខ្ញុំជឿថា លោកអាចារ្យពិតជាសក្តិសិទ្ធិ អាចមើលយល់សេចក្តីពិតទាំងប៉ុន្មាន និងជួយរកវិធីដាស់ស្មារតីឬកែស្រីខ្មោចដែលមានតែសេចក្តីច្រណែននិន្ទាឈ្នានីស លងបន្លាចរើសតែមនុស្សស្រីដូចគ្នា!»

ឃើញជំទាវខ្លួននឹងនរចិត្តហ៊ានបន្ទោសវិញ្ញាណខ្មោចទៅហើយ អ្នកបម្រើជំនិតម្នាល់រាងធាត់កន្ទុកលូកមាត់មកជួយភ្លាមដោយកាយវិការត្រុនៗ៖

«និយាយត្រូវណាស់លោកអាចារ្យអើយ សូម្បីតែកាលនៅរស់ក៏វាមានចរិតដូច្នេះដែរទាន! ប៉ងខ្ពស់ហួសមាឌច្រណែននិន្ទា!»

គ្រាំង....

ស្នូររបើកបង្អួចប្រាវនៅជ្រុងខាងលិចធ្វើឲ្យខ្ញុំជំនិតនៃសេដ្ឋីនី លែងដើរទៅមុខរួចទៀត នៅតោងទាមជាប់ចង្កេះចៅហ្វាយទឹកមុខស្លេកស្លាំងដៃជើងញ័រ។

«លែងយើងយាយអិន!»

ជំទាវអម្ពរគំហកទាំងសម្លក់ទៅបង្អួចនោះ។

«យាយអិនស្គាល់ខ្មោចឬបានជាវាមកគោះបង្អួចហៅយាយ!»

អាចារ្យបង្អើបសួរមកហាក់កំប្លុកកំប្លែងតែយាយអិនស្ទើរនឹងលេចនោមទៅហើយ។ ដោយខ្ញុំចំណាស់នេះ ពាក់អាវតែត្រឹមមួយកំណាត់សុដន់និងចងក្បិនពីសំពត់ សាច់អំបោះពណ៌ស្រគាំដើរទទេ គ្មានពាក់កង គ្មានអលង្ការ តាអាចារ្យដឹងថាមនុស្សក្រីក្រម្នាក់នេះ តោងទាមម្ចាស់ស្រីសុំរស់ ទំនងនឹងដឹងរឿងអតីតច្រើនមិនខានបានជាបន្លចគាត់រកតម្រុយ។

ទាំងសេចក្តីភ័យខ្លាចដូចគ្នាតែធ្វើជាមិនខ្លាច អម្ពរជានារីអភិជនវ័យជ្រេប្រមាណជាង៥០ឆ្នាំ ពេលនេះត្រូវបានខ្ញុំបម្រើអិន ដើរអែបតាមរហូតមកដល់កណ្តាលផ្ទះ។

អាចារ្យដួងនៅទីនេះជាមួយបានកម្លាថា៖

«មិនបាច់អ្នកណាភ័យទេ! យើងដឹងមកតាំងពីរបងខាងក្រៅថាវាមកហើយ មកតាមមើលយើង! វានឹងដឹងស្នាដៃអាចារ្យដួងឥឡូវនេះហើយ!»

អាចារ្យថាចប់កាលណាហើយ ឈានទៅឈរចំចំណុចកណ្តាលផ្ទះ ដោយទុកឱ្យជំទាវនិងបម្រើថយទៅម្ខាងសិន។

ពេលឈរចំចំណុចរកហើយ អាចារ្យងើយសម្លឹងទៅលើធ្នឹមដោយក្រសៃភ្នែកសម្លក់យ៉ាងមុត។ ចំពោះដំបូលផ្ទះឈើបុរាណដែលស្ងួចទៅចំ គាត់នៅសម្លក់យូរណាស់ បណ្ដាលឱ្យគ្រប់គ្នាកើតឆ្ងល់។

«ធ្លាប់តែឃើញគេស្មិងស្មាធ៌បិទភ្នែកហេតុអីបានជាគាត់ស្មិងស្មាធ៌សម្លក់ទៅខាងលើ?»

យាយអិននេះ ខ្សឹបសួរថៅហ្វាយស្រីតិចៗធ្វើឲ្យសេដ្ឋីនីអម្ពរ តាមសម្លឹងអាចារ្យមិនដាក់ភ្នែកដែរ។

នៅឯជាយបន្ទប់ធំនេះ ស្រីក្មេងៗពីរបីនាក់ ស្លៀកពព្លក់សភាពជាបាវបម្រើកំពុងតែប្រតោងគ្នាយ៉ាងភ័យខ្លាចនៅម្ខាងពួកគេ។

ទាំងនោះសុទ្ធតែទាញយកកន្សែងក្រមាមករុំដងខ្លួនព្រោះកន្លងមកជាបាវ មិនមានសិទ្ធិប្រើអាវមួន ឬអាវវែងដូចនាយថៅហ្វាយឡើយ។ ជាច្បាប់បានត្រឹមចងពុម្ពរុំក្រមា។

ត្រូវពេលនេះពួកគេស្លៀកសម្លុយផងក៏ឃើញ ញ័រជើងដូចកណ្ដុរឈ្លក់ទឹក។

អាចារ្យបិទភ្នែកគ្រឹប ភាវនាសូត្រញាប់មាត់នូវសំស្រ្កឹតដូចភាសាឥណ្ឌា។

ភ្លាមនោះ បង្អួចធំៗទាំង៨ទិសស្រាប់តែត្រូវរបូតគន្លឹះធ្លាក់ បិទមកវិញប្រាវៗដោយឯកឯង។

ខ្ញុំបម្រើស្រែកវាសស្រវាឱបគ្នាដួលរេលពេញផ្ទះ.....

ត្រូវសេដ្ឋីនីអម្ពររវៃភ្នែកធំៗប៉ុនពងមាន់ សម្លឹងជុំវិញឃើតៗយ៉ាងស្លុយភ័យផង យាយអិនស្រែកយំសសិតឡើង ទន់ជើងបត់ផ្ទាល់កម្រាលឈើលែងវារឬក្រោកឡើងរួច។

«អាកុក អាគុង បើកបង្អួចវិញ!»

ជំទាវស្រែកកម្លាសេចក្ដីភ័យខ្លាចប៉ុណ្ណោះ។

ភ្នែកជំទាវនេះនៅតែក្រឡេតគ្រលួងនៅឡើយទេ។

អាចារ្យនៅបន្តសូត្រធម៌បិទភ្នែក គឺសូត្រទាំងឈរ ដៃម្ខាងកាន់បង្វិច ម្ខាងទៀតប្រណម។

ព្រិបៗ......

បាវប្រុសៗ២នាក់នៅខាងក្រៅផ្ទះរត់ចូលមកដល់ ហើយបើកបង្អួចដាក់ផ្ទាក់វិញ។ ពួកគេមិនមានពាក់អាវនោះទេ ស្លៀកតែក្បិន និងមានកាន់ដំបងលើដៃម្នាក់មួយផងក្នុងរូបរាងដូចជាអ្នកយាម។

ពេលធ្វើការងារតាមសេដ្ឋីនីបង្គាប់ប្រាប់រួចហើយបម្រុងថាចាកចេញស្រាប់តែអាចារ្យងាកមកហើយបក់ដៃហៅ។

«ឯងទាំងពីរមកនេះ!»

ពួកគេមើលមុខចៅហ្វាយស្រីបន្តិចឃើញថាសេដ្ឋីនីអម្ពរព្រមឱ្យធ្វើតាមអាចារ្យប្រាប់ពួកគេក៏ដើរមកត្រុនត្រុនក្បែរបុរសចាស់មានសិល្ប៍។

អាចារ្យដួងបញ្ជាឡើង៖

«ឯងទាំងពីរនាក់ ដើររកចង្កៀងគ្រប់កន្លែងក្នុងផ្ទះនិងប្រមូលទិញចង្កៀងទាំងអស់នៅក្នុងភូមិបានកាន់តែច្រើនកាន់តែល្អ! ចង្កៀងត្រូវយកប្រភេទណាដែលប្រើប្រេង ហើយយកមករៀបចំឧបកិច្ចដាក់គ្រប់គល់សសរនៅក្នុងផ្ទះធំមួយនេះ!»

បាវព្រាវប្រុសសារជាថ្មីងាកមករង់ចាំបទបញ្ជាពីសេដ្ឋីនី។ សេដ្ឋីនីក៏ញាក់មុខទៅឲ្យយាយអិនដែរ។ យាយនោះក៏យកពីចង្កេះនូវសេនលុយកាក់កញ្ចប់ហុចទៅឲ្យពួកគេ ហើយបង្គាប់៖

«ទៅទិញឲ្យលឿន ធ្វើតាមលោកអាចារ្យទៅ!»

«បាទយាយ!»

អាកុកនិងអាគង់រត់ចេញទៅ។

អាចារ្យងាកមករកកូនសិស្សរបស់ខ្លួនម្នាក់ទៀតរាងទាបទ្រនាប់ដែលកំពុងតែឈររង់ចាំសុភាពរាបសាឆ្ងាយពីគាត់។

ទោះគេខំធ្វើមុខមាំដៃទាំងសងកំពុងឱបនូវសៀវភៅពីរបី តែរាងកូនសិស្សនេះនៅរងាញ័រដូចជាភ័យខ្លាចនៅឡើយ។

ក្មេងនេះមានកោរជប់សល់សក់ខ្មៅមួយដុំតូចនៅខាងមុខ ប៉ុន្តែគេចម្រើនវ័យសឹងថាចូលដល់វ័យកំលោះស្ទែកខានស្ទែកបានទៅហើយ។

«អាមន្ត! ឯងមានឃើញ អ្នកដែលរុញបង្អួចយើងបិទព្រមៗគ្នាគ្រប់ទិសអម្បាញ់មិញនេះដែរ?»

កូនសិស្សកាលបើឮគ្រូសួរហើយក៏លត់ជង្គង់ចុះឆ្លើយតបវិញភ្លាម៖

«ឃើញច្បាស់លោកគ្រូ!»

«ជាអ្នកណា?»

«ជាអរូបម្នាក់នោះហើយ!»

លោកអាចារ្យសួរទៀតខណៈដែលយាយអិននិងអម្ពរឆ្លេឆ្លាកាន់ដៃគ្នាជាប់។

«ឯងឃើញយ៉ាងម៉េចបាន បើអ្នកផ្សេងគេមិនបានឃើញអ្វីសោះ!»

«ឃើញក្នុងចិត្តលោកគ្រូ?!»

«ហេតុអីបានជាអ្នកផ្សេងគេមិនឃើញ ឬអាមន្តឯងចង់ថាពួកគេនេះជាមនុស្សគ្មានចិត្ត?!»

ឯកូនសិស្ស ក៏តមកទៀតរូវៗមិនចេះអាក់ត្រង់ណាចំពោះសំនួរគ្រូឡើយ៖

«ព្រោះពួកគេអាល័យតែមើលនៅក្រៅចិត្តលោកគ្រូ!»

អាចារ្យដួងសើចក្អាកក្អាយ។

កិរិយាគ្រូនិងសិស្សនេះបានធ្វើឲ្យសេដ្ឋីនីដៀងភ្នែកទៅសម្លឹងខ្ញុំបម្រើចំណាស់ហើយគិតក្នុងចិត្តម្នាក់ឯងស្ងាត់ស្ងាត់ថា គ្រូនិងសិស្សនេះកំពុងតែមានបញ្ហាខួរក្បាល ឬមួយក៏និយាយពាក្យផ្លូវងងឹតដែលយើងមិនយល់។

អាចារ្យបោយដៃហៅមន្តមកជិត។

គាត់អង្គុយចុះនៅចំកណ្ដាលផ្ទះនេះ ហើយបង្គាប់ប្រាប់អម្ពរ៖

«ឈប់ខ្លាចទៅ! ពួកឯងឆុងតែថ្នាំក្រអូបមួយកំសៀវឲ្យមកខ្ញុំ ហើយយាយណេះត្រូវឲ្យសេដ្ឋីនីខ្លួនឡើងទៅអង្គុយនៅលើអាសនៈជំនួសប្ដី!»

សេដ្ឋីនីត្រូវបានយាយអិននាំទៅអង្គុយនៅចំកៅអីកណ្ដាលនៃបណ្ដាគ្រឿងសង្ហារឹមពីជួរវែងអន្លាយធ្វើពីឈើបេងខ្មៅរឹងរលោង។

កន្លែងនេះទុកសម្រាប់តែទទួលលៀងភ្ញៀវពន្លឺរបស់ប្ដីដែលតែងតែហ្វឹកហាត់សមមតិ ឬដោយពួកមន្ត្រីដែលចង់មកលេងអុក ហូបស្រា។

ជំទាវបានដល់ទីអង្គុយកាលណាក៏ត្អូញឡើងៈ

«លោកគ្រូអើយ! ច្រើនខែមកនេះដោយសារស្រីព្រាយវាអុកឡុកខ្លាំង គ្មានអ្នកណាគេហ៊ានមកក្បែរផ្ទះនេះទៀតទេ! ទីនេះស្ងាត់ជ្រងំខ្លាំងណាស់លោកគ្រូ! ធ្លាប់អញ្ជើញអាចារ្យមកច្រើនហើយ ប៉ុន្តែដូចជាគ្មានប្រសិទ្ធភាពសោះ!»

«ចុះហេតុអីបានជំទាវមិនមានបញ្ហាអ្វី?!»

«ខ្ញុំមិនដឹងនោះទេ ប៉ុន្តែគ្រប់គ្នាបានឃើញស្រីព្រាយអស់ហើយ នៅឡើយខ្ញុំមិនទាន់បានឃើញ»

«ឬមកពីលោកជំទាវមានយីអ៊ុនខ្ពស់? ជោគជតារាសីថ្កើងមិនអាចឲ្យស្រីព្រាយនោះតាមមកបន្លាចបាន» យាយអិនឆ្លៀតពេលបញ្ចោរចៅហ្វាយ។

អាចារ្យសើចក្អាកក្អាយនៅពេលកូនសិស្សកំពុងតែ លូនក្រាបមកអង្គុយពីក្រោយខ្នងលោកគ្រូ។ គ្រូសួរសិស្សភ្លាមដែរៈ

«ឯងយល់យ៉ាងណាដែលអាមន្ត?»

សិស្សអេះក្បាលហើយងើបមុខចោលភ្នែកសម្លឹងសេដ្ឋីនីនៅលើកៅអីកណ្តាលខ្ពស់ជាងគេ ហាក់គាត់កំពុងរង់ចាំស្តាប់ចម្លើយនាយ។

នាយមន្តចាប់ផ្តើមនិយាយខ្លីៗថាៈ

«មិនមែនទេ មកពីមិនទាន់ដល់ពេលវេលាដែលត្រូវលងបន្លាចម្ចាស់ផ្ទះប៉ុណ្ណោះ!»

ឮហើយសេដ្ឋីនីបើកភ្នែកធំៗសម្លឹងមុខមន្ត រួចក្តោបដៃទាំងសងខាងរំងាប់ភាពភ័យព្រួយ។

ខ្ញុំបម្រើឈ្មោះអិនដែលនៅអង្គុយបត់ជើងក្បែរចៅហ្វាយខ្លួន កាន់តែស្លេកមុខ។ អាចារ្យបន្តសើចក្អាកក្អាយ។

គាត់សើចអស់ចិត្ត ក៏សួរទៅសេដ្ឋីនីទៀតថាៈ

«បើជំទាវមិនដែលឃើញផង ហេតុអីបានជាចាំបាច់អ្វីខ្លាចខ្លាំងម្ល៉េះ?»

«ពួកអ្នកក្នុងផ្ទះនាំគ្នានិយាយឡើងម្តងម្នាក់ៗសុទ្ធតែជារឿងនិទានអំពីព្រាយដែលបង្ហាញខ្លួនធ្វើឲ្យខ្ញុំនឹកឃើញឡើងកាលណាដូចជាបានឃើញនៅចំពោះភ្នែកខ្លួនឯង!»

«ចុះតើជំទាវស្គាល់ព្រាយនោះកាលគេនៅរស់ទេ?!»

ជំទាវអម្ពរទឹកមាត់ចុះឡើងបង្អង់សម្ដីស្ដីឆ្លើយ។ ចំណែកយាយអិនវិញក្ដោបដៃចៅហ្វាយស្រីជាប់ដូចភ័យខ្លាចនិងកំពុងលាក់កំបាំងជួយគ្នាពីរឿងអ្វីម្យ៉ាង។

«តើសេដ្ឋីនីបានធ្វើអ្វីខុសចំពោះមនុស្សស្រីម្នាក់នេះកាលគេនៅរស់ដែរទេ?» អាចារ្យចោទសួរព្រោះពួកគេស្ងាត់ស្ងៀម។

«អត់ទេ! ខ្ញុំគ្មានទេ!»

ជំទាវអម្ពរឆ្លើយឡើងភ្លាមបែបនេះ ធ្វើឲ្យកូនសិស្សឈ្មោះមន្តសើចក្អាកក្អាយវិញម្ដង។

«រហូតទាល់តែមានអ្នកត្រូវសម្លាប់ទើបលោកជំទាវសារភាព?»

«ឈប់ភ្លាម!» យាយអិនសម្លុតនាយមន្ត។

«ខ្ញុំនិយាយការពិតដែលចិត្តខ្ញុំប្រាប់មក!»

យាយអិនសម្លុតទៀតៈ

«ព្រហើន!»

អាចារ្យឃើញកូនសិស្សខ្លួនញោះបានឱ្យចៅហ្វាយនិងកូនព្រាវជំនិតកើតខឹងសម្រេចហើយក៏ងាកទៅមើលប្រតិកម្មរបស់ជំទាវ។ ជំទាវអម្ពរពិតជាបាននឹងកំពុងតែធ្វើមុខក្រញូវមិនស្ដីអ្វីទេ។

«ស្ដាប់ឲ្យបានជំទាវ!»

គាត់និយាយធ្វើឱ្យលោកសេដ្ឋីនីងាកមកភ្លាម។

«ព្រាយនេះតាមចងកម្មពៀរម្ចាស់ផ្ទះ មិនមែនខ្ញុំបម្រើបាវព្រាវទាំងអស់នោះទេ!»

ជំទាវភ្ញាក់សឹងធ្លាក់ពីកៅអី។

អាចារ្យថាឡើងបន្តទៀតៈ

«ប៉ុន្តែពេលនេះជំទាវមករកត្រូវមនុស្ស រឿងទាំងអស់នោះទោះបើកើតឡើងយ៉ាងណា ក៏អាចារ្យដួងនឹងចាត់ការឱ្យបានចប់ឆាប់ៗជូន!»

ជំទាវធូរចិត្ត ព្រោះអាចារ្យក៏ហាក់ដូចជាមិនមានបំណងអ្វីចង់ធ្វើឲ្យលោកជំទាវមានការភ័យខ្លាចបែកជាវែងឆ្ងាយដែរ។

«ដូច្នេះហើយបានជាខ្ញុំអញ្ជើញលោកគ្រូមកជួយណាលោកគ្រូ! ខ្ញុំមិនសាញទ្រនឹបទេ!»

ស្នូរជើងមនុស្សបានចូលមកដល់ច្រើនគ្នា។

នាយកុកនិងនាយគង់ដែលអម្បាញ់មិញចាកចេញទៅរកចង្កៀងប្រេងឥឡូវនាំគ្នាវិលមកវិញជាមួយនឹងកញ្ជេ២ធំពោរពេញទៅដោយចង្រៀងប្រេងតូចធំ ចាស់ថ្មី។

មានគូលីប្រុសពីនាក់ទៀតមិនស្គាល់ឈ្មោះជួយសែងចូលមក។

យើងដើម្បីមិនដឹងថានាយទាំងពីរបានទៅប្រមូលទិញឬក៏យកពីទីណាមកនោះទេ គឺបានមកដល់ទៅរាប់សិបចង្កៀង។

«រាយក្រោមសសរទាំងអស់!»

អាចារ្យបញ្ជាទៅពួកបាវព្រាវប្រុសៗ។

ពួកគេទាំង៤ចាប់ផ្ដើមរាយចង្កៀងទៅតាមគ្រប់មុខសរសរ ផ្ទះនិងពីក្រោមធ្នឹមទាំងឡាយផងតាមដែលអាចារ្យចង្អុលប្រាប់។

ពេលខ្ញុំបម្រើចច្រប់ធ្វើការ អាចារ្យដួងផ្ដាំបន្ថែមៈ

«ព្រាយរម្យនានេះ នាងខ្លាចណាស់ចង្កៀង! នាងស្លាប់ដោយចង្កៀង ដូច្នេះពេលមានចង្កៀងអុជ នាងមិនហ៊ានជាមួយទេ!»

ស្នូរប្រឹបៗលាន់ឡើង!

គ្រប់ចង្កៀងប្រេងកាតនាសសរដងគោម ស្រាប់តែឆេះឆ្លោទាំងអស់ទាំងមានប្រេងក្ដីមិនមានក្ដី។

បម្រើប្រុសភ្ញាក់សឹងរបូតក្បិនធាក់ថយ ខ្លះដួលផ្ងារ ញ័រញាក់ងាកមើលមុខគ្នា។ ជំទាវតោងដៃយាយអិន។

អាចារ្យក៏បើកភ្នែកធំៗដៃរាវរកអង្កាំសិល្ប៍។

«ហាស ហាស ហា! យើងដុតចង្កៀងឱ្យហើយ! ចាំមើលយើងហ៊ានចេញទៅដែរទេអាចារ្យដួង?»

«អ្នកណា?» សេដ្ឋីនីរបូតមាត់សួរញ័រៗតិចទៅកាន់យាយអិន។ ស្រាប់តែសំឡេងខ្សឹបតិចៗសោះបែរជាទទួលបានចម្លើយមកវិញភ្លាមៗ៖

«ឯងសម្លាប់យើងយ៉ាងជួរជាតិ! សំឡេងយើងឯងចំណាំមិនបានទេនាងអម្ពរ?»

សំឡេងរលត់ ខ្យល់បក់បោកប្រោកប្រាកនៅក្រៅផ្ទះ រង្គើអស់ពពួកមែកឈើនាថានសួន។ ការនេះធ្វើឲ្យសេដ្ឋីនី មិនអាចរំងាប់ការភ័យស្លុតបានយូរទៀត ក៏ស្រវាស្ទុះចោលកៅអី ចូលមកក្បែរអាចារ្យដួងដោយពោលបង្គាប់៖

«សម្លាប់វាទៅ!ឆាប់សម្លាប់វាទៅ! វាមកដល់ហើយ!»

អាចារ្យដួងដឹងច្បាស់ថា ជំទាវនេះមានពាក់ព័ន្ធគំនុំជាមួយវិញ្ញាណបានជាខ្លួនឯងត្រូវភ័យស្លុតបាត់ព្រលឹងរត់មកទាំងភ្នែន។

គាត់ចាបផ្តើមលូកស្ពាបអង្គាំសាជាថ្មី ដោយមាត់ពោលបញ្ជាទៅកូនសិស្សមន្ត៖

«អាមន្ត ឯងយកចង្កៀងចំនួនបួនអុចព័ទ្ធជុំវិញលោកជំទាវនេះ!»

«ខ្ញុំសុំនៅផង?!»

យាយអិនហាពោលអង្វរបានតែប៉ុណ្ណេះក៏កាច់កទៅក្រោយផស់ដូចមានអ្នកណាមកជាន់ហើយរលំគ្រេងទៅលើក្តារមិនដឹងនៅដង្ហើមឬផុតហើយទេ។

មន្តនៅបន្តអុចចង្កៀងតាមបញ្ជាគ្រូមិនមានញាប់ញ័រអ្វីទាំងអស់ ខណៈពួកប្រុសៗជាបាវព្រាវរត់ស្រចេញក្រៅរត់ប្រាស់ ខ្លះឱបសសរពួនបិទភ្នែក។ ស្រីៗជាខ្ញុំបម្រើដែលតោងគ្នាដួលសន្លប់ជាបន្តបន្ទាប់ទៅ។

អាចារ្យដួងយកអំបោះបួនខ្សែសុទ្ធសឹងតែមានពណ៌ខ្មៅមកចងក្រោមចង្កៀងទាំងបួនដោយសូត្រធម៌ញាប់ផង។ ចប់ភារៈក៏ចយ មកអង្គុយធ្មេចភ្នែកពែនភ្នែនប្រណម្យនៅចំកណ្តាលផ្ទះបែរមកចំជំទាវ។

«ស្រីព្រាយអប្បលក្ខ! ឯងមកយាយីមនុស្សនេះមិនបានទេហង!»

សំណើចអមនុស្សចាប់ផ្តើមលាន់ឡើងពីគ្រប់បង្អួចទាំងប្រាំបី។ អាចារ្យស្រែកបង្គាប់ទៀត៖

«ឯងដេកទៅអាមន្ត!»

នាយមន្តផ្កាប់មុខដេកបិទភ្នែកជិត។

«លោកជំទាវសម្លឹងមកខ្ញុំកុំដាក់ភ្នែក កុំងាកទៅណាទោះជាបានឮអ្វីក៏ដោយ!»

សេដ្ឋីនីត្រូវតាបង្គាប់ហើយ ក៏ធ្វើតាមដោយខំខ្ទប់មាត់លែងស្រែកលែងញ័រញាក់។

ពេលម្ចាស់ផ្ទះ ទប់ស្កាត់ភាពភ័យខ្លាចបានហើយ តាអាចារ្យនិយាយឡើងថា ៖

«ស្រីព្រាយកម្លៅ តើឯងចង់បានអ្វី?»

សំឡេងអមនុស្សឆ្លើយតបល្វើយៗ៖

«យើងចង់ទារជីវិតរបស់យើង!»

«យើងគ្មានជីវិតឱ្យទេ ឯងស្លាប់បង់ហើយ បានជីវិតឯណាវិញ? បើឯងមិនទៅមុខ រកភពថ្មីរបស់ឯង វិញ្ញាណឯងនឹងត្រូវបញ្ចប់គ្រប់យ៉ាងនៅថ្ងៃនេះ ក្រោមដៃព្រះគ្រូដ៏អស្ចារ្យរបស់យើង!»

អរូបសើចក្អាកក្អាយប្រណាំងជាមួយនឹងសំឡេង ខឹងសម្បាលន្លោងលន្លោចបង្ហួសរហូតមកពីខាងក្រៅ។ ទ្វារបង្អួចប៉ើងបែកខ្ទាត់ខ្ទាយទោះឈើធុនមាំមានតម្លៃនិងមានទម្ងន់ធ្ងន់យ៉ាងណាគង់តែទប់ខ្យល់អសុរីមិនបានឡើយ។

សន្ទុះខ្យល់លាន់ឡើងជាលំដាប់ រហូតដល់សេដ្ឋីនីអស់សមាធិភ្លាត់មាត់ស្រែកវ៉ាស់ព្រោះភ័យខ្លាច តែរលំដោយទាំងបណ្តាសសរផ្ទះសង្កត់ស្លាប់ខ្លួន។

អាចារ្យស្រែកឡើងថា៖

«មិនបាច់ភ័យខ្លាចអ្វីទាំងអស់!»

គាត់ក្រឡេចមាត់ងាកទៅរកទ្វារធំ ស្រាប់តែឃើញគំនួចខ្យល់ខ្មៅមួយក្ដួចហួរចូលមកដល់លេចចេញជារូបរាងស្រមោលមនុស្សស្រីម្នាក់បើកភ្នែកធំយោលយោគលើលំហ។

សេដ្ឋីនីដៀងចំហៀងខ្លួន ឃើញហើយក៏សឹងថា គាំងលែងនិយាយអ្វីរួច ព្រោះតែសេចក្ដីតក់ស្លុត។

អម្ពរទាញ ជើងរបស់ខ្លួនមករួញខ្លីលាក់ក្នុងសីម៉ានៃចង្កៀងទាំងបួន។

ខ្យល់ធំប៉ុនណាហើយក៏ចង្កៀងនេះ មិនបានរលត់ទេ។

សេដ្ឋីនីពិនិត្យចង្កៀងនិងសសៃអំបោះខ្មៅរួចក៏កើតនឹកអាងគ្រូអាចារ្យដ៏មានមហិទ្ធិឫទ្ធិថាកំពុងនៅក្បែរការពារខ្លួន ដូច្នេះក៏អន់ភ័យងើបមុខសម្លឹងទៅកាន់ព្រាយបិសាច។

«មនុស្សឯងកាលនៅរស់ធ្វើអីយើងមិនបានផងចុះទម្រាំពេលនេះឯងមានតែព្រលឹងនាងរម្យនា !»

បិសាចកាន់តែខឹងសម្បាគ្រហឹមខ្ទរផ្ទះធំ។

សន្ទឹកខ្យល់វេទមន្តខ្មៅ បង្កើនឫទ្ធាខ្ទរខ្ទារសឹងតែដាច់បង្អួចទាំងប្រាំបីចោលបង់ទៅ។ ប៉ុន្តែសេដ្ឋីនីបានចិត្តហើយអន់ការភ័យខ្លាចជាលំដាប់ដោយសារឃើញថាអាចារ្យចាប់ផ្ដើមសូត្រធម៌យ៉ាងញាប់និងធ្វើឲ្យបែកសាយបណ្ដើរៗ នូវគំនួចខ្យល់ខ្មៅរូបមនុស្សស្រី។

សូត្រពីនេះមិនអស់ចិត្ត តាក្រោកឡើងដើរទាំងប្រណមសូត្រជាប់មាត់ឆ្ពោះទៅប្រឈមនៅពីមុខគំនួចខ្យល់ធ្វើឱ្យវិញ្ញាណត្រូវស្រែករោទ៍ដោយសេចក្ដីឈឺចាប់។

ជំទាវមើលពីទីនេះទៅ ហាក់បីដូចជា ធម៌នោះ ក្លាយទៅជាអំណាចមួយរុំព័ទ្ធជារបង កំពុងវាយប្រហារចងរឹតរួត លើព្រលឹងវិញ្ញាណរបស់អរូបដូច្នោះដែរ។

ពេលវាកាន់តែស្រែកសន្ធាប់ដៃម្ខាងរបស់អាចារ្យបានរាវរកក្នុងថង់ចង្កេះបានដកកូនឃ្លោកមួយតូច រាងដូចជាចង្កៀងប្រេងដែរតែធម្មជាតិតវាជាឃ្លោកស្ងួត។

វាមានចងអំបោះខ្មៅដែរ។

ដៃម្ខាងខ្លួនដែលបើកគម្របរបស់វា គ្រូអាចារ្យបានធ្វើឱ្យស្រីព្រាយស្រែកភ័យឡើង។ នាងនេះចង់ ចាប់ផ្ដើមរត់គេចថយទៅក្រៅផ្ទះតែគំនួចនេះត្រូវចងបានដោយសិល្ប៍ទៅហើយ គេចទៅណាមិនរួចមានតែស្រែករោទ៍ខ្លាចការស្រូបទាញវិញ្ញាណទៅឃុំ។

«កុំៗៗៗ»

អាចារ្យកាន់តែសូត្រញាប់និងលាកូនឃ្លោកទៅលើបាតដៃ។ សំឡេងបាលីជាប់រន្ថើននេះញ៉ាំងឱ្យព្រាយអសុរកាយត្រូវរួមរឹតស្រែករោទ៍ហើយវិញ្ញាណរបស់នាងដែលកំពុងអណ្ដែតនៅក្នុងលំហខ្យល់ ទីបំផុតបានរួមតូចល្អិតឡើងៗ នឹងធ្លាក់របូតចូលទៅក្នុងដបឃ្លោកស្ងួតមែន។

អាចារ្យបានបំបិទឆ្នុកពីលើយ៉ាងរហ័ស។

«ហាហាហា ចប់ហើយ!»

សេដ្ឋីនីញញឹមដោយមិនមានសំឡេងនៅពេលឮគ្រូអាចារ្យរីករាយអបអរជ័យជម្នះ។

មន្តក្រោកឡើង មើលទៅគ្រូអាចារ្យខ្លួនដែលកំពុងកាន់កូនឃ្លោកនៅលើបាតដៃ។

សំឡេងនាងព្រាយនៅតែបន្តតវ៉ា៖

«អាចារ្យកំណាច ឯងដឹងរឿងយើងថាស្លាប់ដោយអយុត្តិធម៌ហើយ ម្តេចនៅតែបន្តជួយឃុបឃិតនឹងមនុស្សកំណាចធុននាងអម្ពរនេះ!»

សេដ្ឋីនីបានបង្ហាញទឹកមុខអំនួត។

នាងគិតថា សត្រូវបានត្រូវឃាំងដោយបាលីជាប់នៅក្នុងនេះហើយ គង់គ្មានថ្ងៃណាចេញមកអុកឡុកបានទៀតទេ ក៏ឈប់ស្លេកស្លាំងហើយញញឹមញញែម។

«ជំទាវក្រោកមកបាន!»

អាចារ្យប្រាប់ពីនេះទៅ។

ជំទាវឈានឡើងមកវិញចោលគំនូសសីមានៃចង្កៀងប្រេងធ្វើឱ្យឃ្លោកបោកកញ្ជ្រោលមិនសុខចិត្តទេ។ នាងព្រាយស្រែកយំយែកថា៖

«អាចារ្យឥតធម៌! ឯងជួយមនុស្សអាក្រក់ដើម្បីទ្រនឹប យើងដាក់បណ្តាសាឯង....»

មិនឱ្យខ្មោចបានថានូវពាក្យបណ្តាសាឡើយ អាចារ្យដួងប្រញាប់រួសរាន់ប្រើទ្រាមមួយសរសេរជាអក្សរបាលី បង្រ្កបលើសំឡេង អក្សរគួរមើលមិនឃើញត្បិតគ្មានជក់គ្មានថ្នាំ តែសរសេរលើដបចប់កាលណាក៏ព្រាយរលត់ឈឹបសំឡេងនាង។

ឃ្លោកនៅខំរង្គើទាំងគ្មានសំឡេងតវ៉ា។

អាចារ្យនិយាយឡើង៖

«យើងជាអ្នកចាប់ខ្មោច! គ្មានភារៈតាមរកយុត្តិធម៌ឱ្យអ្នកណាទេ! យើងចាប់ឯងហើយ បើអ្នកណាសម្លាប់ឯងឬធ្វើកម្មជាមួយឯង ជាភារៈនៃក្រុមយមបាល មិនមែនយើងដាច់ខាតនាងរម្សនា! ឯងកុំបន្ទោសយើង!»

ដល់និយាយរួច ក៏ងាកមកនិយាយប្រាប់សេដ្ឋីនីថា៖

«មានកម្មវិធីបន្ថែមច្រើនទៀត ឆាប់រកកន្លែងសមគួរដើម្បីកប់របស់នេះ!»

សេដ្ឋីនីក៏សួរវិញថា

«ផ្ទះនេះធំណាស់ តើគួររកប៉កន្លែងណាទៅទាន?»